# ២៣០២៤៧ – ព័ត៌មានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពប្រចាំសប្តាហ៍

លេខរៀងទី៤៧

១៣ កុម្ភៈ ២០២៣-១៩ កុម្ភៈ ២០២៣

រៀបរៀងដោយ សុខ ច័ន្ទសុភា អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលនៃការសិក្សាអភិវឌ្ឍន៍ប្រកបដោយចីរភាព

## ជប៉ុន សន្យាបន្តគាំទ្រកម្ពុជាទប់ស្កាត់ការបំពុលដោយប្លាស្ទិកក្នុងសមុទ្រ

ជប៉ុនបានប្រកាសសន្យាបន្តការគាំទ្រដល់កម្ពុជា ក្នុងការគ្រប់គ្រងសំរាមប្លាស្ទិក និងទប់ស្កាត់ការបំពុលដោយប្លាស្ទិកក្នុងសមុទ្រ។ការសន្យាបែបនេះធ្វើឡើង ក្នុងឱកាសលោក តានិណៃ អ៊ិឈិតុម៉ុ អនុប្រធានបេសកកម្មការទូតនៃស្ថានទូតជប៉ុនប្រចាំកម្ពុជា បានចុះពិនិត្យ «គម្រោងទប់ស្កាត់សំណល់ប្លាស្ទិកសមុទ្រនៅកម្ពុជា» នៅខេត្តព្រះសីហនុ កាលពីនៅថ្ងៃទី១៥ ខែកុម្ភៈ។ ស្ថានទូតជប៉ុន បញ្ជាក់ថា ក្នុងទំព័រហ្វេសប៊ុកផ្លូវការរបស់ខ្លួន នាថ្ងៃទី១៧ ខែកុម្ភៈ គម្រោងនេះជាជំនួយបច្ចេកទេស និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលជប៉ុន តាមរយៈកម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UNDP) ប្រចាំនៅកម្ពុជា ដែលអនុវត្តដោយក្រសួងបរិស្ថាន ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលដោយប្លាស្ទិក នៅលើគោក និងក្នុងសមុទ្រ។ ការកាត់បន្ថយការបំពុលដោយ ប្លាស្ទិក នេះធ្វើឡើងតាមរយៈការផ្សព្វផ្សាយគោលការណ៍ ៤ក គឺ «កុំប្រើ កាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងកែច្នៃ»។ ស្ថានទូតជប៉ុនបញ្ជាក់ថា៖ «រដ្ឋាភិបាលជប៉ុន នឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីគាំទ្រដល់កម្ពុជាក្នុងការគ្រប់គ្រងសំរាមប្លាស្ទិក និងទប់ស្កាត់ការបំពុលដោយប្លាស្ទិកក្នុងសមុទ្រ»។៚

ប្រភព: [The Phnom Penh Post]

## ក្រសួងយុត្តិធម៌ចុះអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការគ្នាជាមួយនឹងឧត្តមក្រុមប្រឹក្សាសារការីនៃសាធារណរដ្ឋបារាំង

ក្រសួងយុត្តិធម៌ ដែលតំណាងដោយលោក កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានចុះអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការជាមួយនឹងឧត្តមក្រុមប្រឹក្សាសារការីបារាំង ដែលតំណាងដោយលោកសារការី Jean Deleage តំណាងឧត្តមក្រុមប្រឹក្សាសារការីបារាំង ប្រចាំតំបន់អាស៊ីអាគ្នេយ៍នាថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២៣ នេះ។ ពិធីនេះមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងយុត្តិធម៌, លោកJacques Pellet ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា, លោកស្រី Béatrice Balivet ទីប្រឹក្សាអមក្រសួងយុត្តិធម៌ ព្រមទាំងលោក Olivier Gout ព្រឹទ្ធបុរសមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យ Jean Moulin Lyon 3 ផងដែរ។ លោករដ្ឋមន្ត្រីបានបញ្ជាក់ក្នុងឱកាសនោះថា ការចុះហត្ថលេខាលើអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការនាពេលនេះ គឺជាការបើកទំព័រថ្មីមួយទៀតនៃការពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ សំដៅជួយឱ្យវិជ្ជាជីវៈសារការីនៅកម្ពុជាកាន់តែមានភាពល្អប្រសើរឡើង។ តាមរយៈការអនុវត្តអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការថ្មីនេះ ឧត្តមក្រុមប្រឹក្សាសារការីបារាំងនឹងជួយកម្ពុជាលើការងារសំខាន់ៗ ជាអាទិ៍៖ (ទី១) ការជួយរៀបចំនូវក្របខ័ណ្ឌគតិយុត្តដ៏រឹងមាំមួយសម្រាប់ការបង្កើត ការគ្រប់គ្រង និងការអភិវឌ្ឍវិជ្ជាជីវៈសារការីនៅកម្ពុជាតាមប្រព័ន្ធឡាតាំងផង និងឱ្យសមស្របតាមតម្រូវការជាក់ស្តែងនៃសង្គមកម្ពុជាផង, (ទី២) ការបន្តលើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់សិស្សសារការី និង សារការីដែលកំពុងប្រកបវិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការប្រកបវិជ្ជាជីវៈសារការីនៅកម្ពុជាឱ្យកាន់តែទទួលបានជំនឿទុកចិត្ត និងការទទួលស្គាល់កាន់តែទូលំទូលាយពីសាធារណជន និង (ទី៣)ការជួយរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ការបង្កើត និងគ្រប់គ្រងវិជ្ជាជីវៈសន្ទានការី ដែលជាវិជ្ជាជីវៈថ្មីមួយសម្រាប់កម្ពុជា។៚

ប្រភព: [The Phnom Penh Post]

### អណ្ដើកហ្លួងចំនួន ១៥ ក្បាល ត្រូវបានប្រគល់ជូនវិទ្យាស្ថានជាតិស្រាវជ្រាវ និងអភិវឌ្ឍវារីវប្បកម្ម សម្ដេចតេជោ ហ៊ុន សែន ក្នុងខេត្តកណ្ដាល

អង្គការ WCS សហការជាមួយរដ្ឋបាលជលផលនាថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០២៣ បានយកអណ្ដើកហ្លួងចំនួន ១៥ ក្បាលពីមជ្ឈមណ្ឌលអភិរក្សសត្វល្មូនកោះកុង ទៅប្រគល់ជូនវិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្ម សម្ដេចតេជោ ហ៊ុន សែន ដែលមានទីតាំងស្ថិតនៅក្នុងឃុំរកា ខេត្តកណ្ដាល។ យោងតាមអង្គការ WCS បានឱ្យដឹងនៅថ្ងៃទី ១៧ ខែកុម្ភៈនេះថា ក្នុងចំណោមអណ្ដើកទាំង ១៥ ក្បាលនោះ មានញីចំនួន ១ ក្បាល ឈ្មោលចំនួន ១ ក្បាល និង ១៣ ក្បាលទៀតមានវ័យស្ទើរជំទង់ដែលមិនទាន់ដឹងភេទនៅឡើយនោះទេ។ អង្គការ WCSបានបញ្ជាក់ថា៖« ការប្រគល់នេះ គឺជាការឆ្លើយតបទៅនឹងសំណើរបស់ថ្នាក់ដឹកនាំនៃវិទ្យាស្ថានខាងលើដែលបានស្នើសុំយកប្រភេទអណ្ដើកនេះទៅចិញ្ចឹមនៅក្នុងវិទ្យាស្ថានក្នុងគោលបំណងឱ្យនិស្សិតបានធ្វើការសិក្សាស្រាវជ្រាវអំពីជីវសាស្ត្ររបស់ប្រភេទនេះផង និងដើម្បីបង្កាត់ពូជផង។ វិទ្យាស្ថាននោះមានផ្ទៃដីសរុបប្រមាណ ៣០ហិកតា»។

ប្រភព: [*The Phnom Penh Post*]

### ខេត្តព្រះវិហារមានគោលដៅប្រែក្លាយទៅជាខេត្តកសិសរីរាង្គ

លោក គឹម រិទ្ធី អភិបាលខេត្ត បានប្រាប់ទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP) ថា ខេត្តព្រះវិហារកំពុងធ្វើការប្រែក្លាយទៅជាខេត្តកសិសរីរាង្គមួយនៅកម្ពុជា។ វិស័យកសិកម្មជាវិស័យសក្ដានុពលរបស់ខេត្ត បូករួមទាំងធនធានដែលមានស្រាប់ដូចជា ស្រូវសរីរាង្គ ស្វាយចន្ទីសរីរាង្គ ក៏ដូចជាដំឡូងមីសរីរាង្គ ដែលទទួលបានការស្វាគមន៍ពីសាធារណជនរួចហើយ ដោយលោកបានសង្កត់ធ្ងន់ថាខេត្តបាននិងកំពុងលើកកម្ពស់ការធ្វើកសិកម្មសរីរាង្គក្នុងចំណោមកសិករទូទាំងខេត្ត។ លោក គឹម រិទ្ធី មានប្រសាសន៍ថា កសិកម្មសរីរាង្គត្រូវបានចាត់ទុកថាមានតម្លៃបន្ថែម ហើយកសិករអាចលក់កសិផលសរីរាង្គរបស់ពួកគេបានថ្លៃជាងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ឬជីគីមី ទោះបីជាផលិតផលសរីរាង្គមានទិន្នផលទាបជាងក៏ដោយ។ លោកអភិបាលខេត្តមានប្រសាសន៍ថា ខេត្តព្រះវិហារមានសក្ដានុពលច្រើនលើផ្នែកកសិកម្មសរីរាង្គ។ រហូតមកដល់ពេលនេះ កសិករភាគច្រើនបានដាំដំណាំតាមបែបប្រពៃណី។ ដើម្បីសម្រេចបាននូវគោលគំនិតនេះ លោកបានបន្តថា យើងត្រូវធ្វើឱ្យភូមិទាំងអស់ក្លាយជាភូមិសរីរាង្គ។ នៅពេលដែលភូមិនីមួយៗមានសរីរាង្គ ខេត្តព្រះវិហារនឹងក្លាយទៅជាខេត្តដំណាំសរីរាង្គ។ យ៉ាងណាក៏ដោយ ខេត្តកំពុងជំរុញឲ្យក្រុមហ៊ុនឯកជន ដាក់ការបញ្ជាទិញ នៅថ្នាក់ភូមិ និងសហគមន៍។

ប្រភព: [*Khmer Times*]

### ទិវាសម្អាតអនាម័យអបអរថ្ងៃកំណើតកាកបាទក្រហមកម្ពុជា ១៨កុម្ភៈ

នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣ សាខាកាកបាទក្រហមកម្ពុជា ខេត្តសៀមរាប បានរៀបចំពិធី សម្អាតអនាម័យនៅបរិវេណឧទ្យានសហស្សវត្សរ៍កាកបាទក្រហមកម្ពុជា ដើម្បីអបអរសាទរខួប លើកទី៦៨ ថ្ងៃកំណើតកាកបាទក្រហមកម្ពុជា (១៨ កុម្ភៈ ១៩៥៥-១៨ កុម្ភៈ ២០២៣)។ មន្ត្រីពាក់ព័ន្ធ និងយុវសិស្សសរុប ១៥០នាក់ បានចូលរួមក្នុងទិវាសម្អាតអនាម័យនៅឧទ្យាន សហវត្សរ៍កាកបាទក្រហមកម្ពុជា។ ពួកគេបានធ្វើពលកម្មសម្អាតបរិស្ថានក្នុងឧទ្យានសហស្សវត្សរ៍ កាកបាទក្រហមកម្ពុជា ដោយក្រីមែកឈើ បោសស្លឹកឈើងាប់ ជម្រះស្មៅធ្វើជាផ្លូវការពារភ្លើងឆេះ ដែលអាចរាលដាលដល់ដើមឈើក្នុងឧទ្យានសហស្សវត្សរ៍ដោយថាហេតុណាមួយផង ជាពិសេសដើម្បីបញ្ជាក់ពីសកម្មភាពចូលរួមរបស់ប្អូនៗយុវជនកាកបាទក្រហមកម្ពុជា ដូចដែលទិសស្លោកបានលើកឡើងថា "សកម្មនៅមូលដ្ឋាន សម្រេចបានគោលដៅសកល" ផងដែរ។ ជាមួយគ្នានេះដែរ មន្ត្រីដែលមកពីខណ្ឌរដ្ឋបាលព្រៃឈើខេត្ត គឺជាមន្ត្រីជំនាញពួកគាត់បានធ្វើការ ក្រីតាក់តែង កាប់មែកឈើដែលចាស់ៗចោល ដើម្បីឱ្យដើមរបស់វាអាចលូតលាស់បានល្អ និងកាប់កូនឈើតូចៗគ្មានប្រយោជន៍ចោលផងដែរ។

ប្រភព: [*Khmer Times*]

### កូរ៉េខាងត្បូងថា ការខ្វះស្បៀងអាហារនៅប្រទេសកូរ៉េខាងជើង ទំនងជាកាន់តែអាក្រក់ទៅៗ

ក្រសួងបង្រួបបង្រួមកូរ៉េខាងត្បូង បាននិយាយកាលពីថ្ងៃពុធថា ការខ្វះខាតស្បៀងអាហារនៅប្រទេសកូរ៉េខាង ជើង ទំនងកាន់តែអាក្រក់ ទៅៗ ចំពេលមានរបាយការណ៍ព័ត៌មានថា កូរ៉េខាងជើងថ្មីៗនេះ បានកាត់បន្ថយរបបអាហារពីយោធា។ កូរ៉េខាងជើង បានទទួលស្គាល់ភាពធ្ងន់ធ្ងរនៃការខ្វះខាតស្បៀងអាហាររបស់ខ្លួន ខណៈដែលខ្លួនបានហៅការអភិវឌ្ឍកសិកម្មថា ជាកិច្ចការ «បន្ទាន់ណាស់» សម្រាប់ឆ្នាំនេះ។ នេះបើយោងតាមក្រសួងដែលគ្រប់គ្រងកិច្ចការអន្តរកូរ៉េ។ កាសែត DongA Ilbo ជា

កាសែតប្រចាំថ្ងៃបានរាយការណ៍កាលពីថ្ងៃពុធថា កូរ៉េខាងជើងបានកាត់បន្ថយអាហារប្រចាំថ្ងៃ ដែលផ្តល់ឱ្យទាហានពី ៦២០ ក្រាម មកត្រឹម ៥៨០ ក្រាម ក្នុងទាហានម្នាក់ជាការកាត់បន្ថយលើកដំបូង នៅក្នុងទសវត្សរ៍ឆ្នាំ ២០០០។ ដោយថ្លែងនៅក្នុងសម័យប្រជុំគណៈកម្មាធិការសភារដ្ឋមន្ត្រីបង្រួបបង្រួមជាតិ លោក Kwon Youngse បាននិយាយថា កូរ៉េខាងជើងត្រូវបានគេ និយាយថា បានស្នើសុំឱ្យកម្មវិធីស្បៀងអាហារពិភពលោកផ្តល់ជំនួយស្បៀងអាហារ ដោយសារវិបត្តិស្បៀងអាហាររបស់ខ្លួនកាន់តែយ៉ាប់យ៉ឺនទៅហើយ។ លោក Kwon បាននិយាយថា ស្ថានភាពរបស់កូរ៉េខាង ជើងហាក់ដូចជាមិនបានឈានដល់ចំណុចមួយ ដែលមនុស្សស្លាប់ដោយការស្រេកឃ្លាន ដូចអ្វីដែលគេបានឃើញក្នុងអំឡុងពេល Arduous March (ក្នុងទសវត្សរ៍ឆ្នាំ ១៩៩០) ទេ។ ប្រទេសកូរ៉េខាងជើង គ្រោងនឹងរៀបចំកិច្ចប្រជុំពេញអង្គ មួយនៅចុងខែនេះ ដើម្បីពិភាក្សាអំពីបញ្ហាស្បៀងអាហារ ដែលអ្នកសង្កេតការណ៍បាននិយាយថា ចង្អុលទៅតម្រូវការបន្ទាន់របស់ខ្លួន ដើម្បីដោះស្រាយវិបត្តិស្បៀងអាហារ។៕

**ប្រភព:** ***The Phnom Penh Post***


**មជ្ឈមណ្ឌលនៃការសិក្សាអភិវឌ្ឍន៍ប្រកបដោយចីរភាព**

អាស័យដ្ឋាន: ផ្ទះលេខ២៤ ផ្លូវ៥៦៦ សង្កាត់ បឹងកក់២ ខណ្ឌ ទួលគោគ រាជធានី ភ្នំពេញ

**Email**: admin@asianvision.org

**Facebook**: Asian Vision Institute

**Twitter**: Asian Vision Institute (@vision_asian)

**Telegram**: AVI Channel (https://t.me/asianvision)

# 230247 – AVI Sustainable Development Goals Weekly News Digest, Issue 47

## 13th February – 19th February 2023

## By: SOK Chansophea (Junior Researcher, CSDS)

### Japan reaffirms support for Kingdom's fight against marine plastic pollution

Japan on February 17 reaffirmed its support for Cambodia's management of plastic waste and battle against marine plastic pollution. The pledge came two days after Ichitomo Taninai, deputy chief of mission of the Japanese embassy, made a site visit to Sihanoukville for the "Combating Marine Plastic Litter in Cambodia" project, as noted by the Japanese embassy in a statement. "The project is a technical and financial support by the Government of Japan through UNDP Cambodia, and implemented by the Ministry of Environment to prevent and minimise plastic pollution on land and in the ocean through promotion of a 4R – Refuse, Reduce, Reuse and Recycle – framework," it said. "Japan will continue to support Cambodia's efforts in management of plastic litter and help prevent additional marine plastic pollution," it vowed.

**Source: *The Phnom Penh Post***

### Justice minister inks MoU with French Superior Council of Notaries

Minister of Justice Koeut Rith on February 17 signed a memorandum of understanding (MoU) on cooperation with the French Superior Council of Notaries (CSN). The deal was also inked by Jean Deleage, CSN Southeast Asia representative, at a ceremony held in the presence of justice ministry leaders, French ambassador Jacques Pellet, and Jean Moulin University Lyon 3 representatives Beatrice Balivet and Olivier Gout. Under the MoU, the CSN will help Cambodia with a three main tasks, marking a "new page" in cooperation between the two institutions and the notary profession in Cambodia, the minister said.

The first is the preparation of a solid legal framework for the establishment, management and development of the notary profession in Cambodia, according to the "Latin system" and the practical needs of society, Koeut Rith said. The second is the training and capacity-building of notary students to enhance quality and effectiveness, as well as promote public recognition, trust and confidence of and in the profession, he said. The third is the preparation of a law and legal standards for the establishment and management of the mediator profession, which is relatively new in Cambodia, he added.

**Source: *The Phnom Penh Post***

### WCS Cambodia hands over 15 royal turtles to 'third assurance colony'

Wildlife Conservation Society (WCS) Cambodia announced that it had handed over 15 royal turtles to the "National Aquaculture Research and Development Institute Samdech Techo Hun Sen, located in Roka commune, Kandal province" on February 16, in collaboration with the Fisheries Administration (FiA) under the Ministry of Agriculture, Forestry and Fisheries. The turtles included two sub-adults – one male, one female – and 13 juveniles, WCS Cambodia affirmed in a February 17 statement. "The institute covers an area of approximately 30ha. The purpose is to have them at the institute for students to study their biology, as well as for breeding. "Transferring some of these critically endangered turtles for breeding in different places will allow to better protect and conserve the species from extinction. "This is the third assurance colony of its kind, after WCS's Koh Kong Reptile Conservation Center in Koh Kong province and Angkor Center for Conservation of Biodiversity in Siem Reap province. WCS will provide

technical support as needed, to ensure the reptiles stay healthy," it said.

**Source: *The Phnom Penh Post***

## Preah Vihear aims to become an organic farming province

Provincial Governor Kim Rithy told the Cambodian News Agency (AKP) that Preah Vihear was transforming into an organic farming province in Cambodia. Agriculture is a potential sector of the province, including existing resources such as organic rice, organic cashews, as well as organic cassava, which have already been welcomed by the public. Emphasizing that the province has been promoting organic farming among farmers across the country. Mr. Kim Rithy says that organic farming is considered value-added, and farmers can sell their organic products more expensively than using pesticides or chemical fertilizers even if organic products have lower yields. The provincial governor said that Preah Vihear province has a lot of potential in the field of organic agriculture. So far, most farmers have grown traditional crops. To achieve this concept, he said. He added that we need to make all villages organic. Once each village has an organic farms, Preah Vihear will become an organic crop province. Currently, the province is urging private companies to place orders at the village and community levels.

**Source: *Khmer Times***

## Clean-Up Day to Celebrate the Birthday of the Cambodian Red Cross

On February 17, 2023, the Cambodian Red Cross branch in Siem Reap organized a clean-up ceremony at the Cambodian Red Cross Millennium Park to celebrate the 68th anniversary of the Cambodian Red Cross (February 18, 1955 - February 18, 2023). A total of 150 officials and students participated in a clean-up day at the Cambodian Red Cross Millennium Park. They worked to clean up the environment in the Cambodian Red Cross Millennium Park by cutting down dead branches, clearing weeds as a way to prevent fires that could eventually spread to the trees in Millennium Park, especially to confirm their will to participate. The young people of the Cambodian Red Cross, as the saying goes, "be active at the grassroots to achieve global goals." At the same time, the officials from the Provincial Forestry Administration and professional officers worked hard to cut down the old branches so that their stems could grow well and cut down the useless saplings.

**Source: *Khmer Times***

## South Korea says food shortage in North Korea is likely to worsen

South Korea's unification ministry said Wednesday that food shortages in North Korea are likely to worsen amid reports that North Korea has recently cut back on its military. North Korea has acknowledged the seriousness of its food shortages as it called agricultural development "urgent" for this year. This is according to the Ministry of Inter-Korean Affairs. North Korea reduced its daily food rations from 620 grams to 580 grams per soldier for the first time in the 2000s, the daily DongA Ilbo reported on Wednesday. Speaking at a meeting of the National Unification Committee, Kwon Youngse said North Korea was said to have asked the World Food Program for food aid as its food crisis worsened. Kwon said the situation in North Korea did not appear to have reached the point where people died of starvation as seen during the Arduous March (1990s). North Korea is scheduled to hold a plenary session later this month to discuss food issues, which observers say point to its urgent need to address the food crisis.

**Source: *The Phnom Penh Post***

**Centre for Sustainable Development Studies,**
**AVI Address**: #24, Street 566, Boeung Kok 2, Toul Kok, Phnom Penh, Cambodia
**Email**: admin@asianvision.org
**Facebook**: Asian Vision Institute
**Twitter**: Asian Vision Institute (@vision_asian)
**Telegram**: AVI Channel (https://t.me/asianvision)